អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ភារវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ទស្សនៈរបស់លោកមហាត្មគន្ធី
## អតីតប្រធានាធិបតីប្រទេសឥណ្ឌាប្រៀបមកព្រះពុទ្ធសាសនា ។

www.hoksavann.org

ថ្ងៃទី២១ មិថុនា ២០១២



លោកមហាត្មគន្ធី អតីតប្រធានាធិបតីនៃសហភាពឥណ្ឌា ដែលគេយល់ថា គាត់ទាមទារឯករាជ្យពីប្រទេសអង់គ្លេសដោយធម៌អហិង្សា តែគាត់ត្រូវគេបាញ់សម្លាប់ ។ អ្នកនយោបាយពិភពលោក ទោះបីអ្នកនយោបាយខ្លះមិនយកទស្សនៈរបស់គាត់ទៅអនុវត្តក្នុងការដឹកនាំរបស់ខ្លួនក៏ដោយ ក៏បានកោតសរសើរនូវទស្សនៈរបស់គាត់ដែរ ហើយប្រវត្តិរបស់គាត់បានត្រូវគេលើកយកមកថតជាភាពយន្តទៀតផង ។ ពេលនេះ យើងសូមលើកយកទស្សនៈរបស់គាត់ខ្លះ មកប្រៀបធៀបនឹងព្រះពុទ្ធសាសនា ។

មហាត្មគន្ធីមានប្រសាសន៍ថា ការស្រែកសូមសេចក្តីករុណាអំពីអ្នកដទៃ គឺជាការពពាយនាយលក់ឥស្សរភាពរបស់ខ្លួន ។ គឺគាត់យល់ថា ការសូមឲ្យអ្នកដទៃអាណិតអាសូរដល់ខ្លួន គឺជាភាពមនុស្សទន់ខ្សោយគ្រប់គ្រងខ្លួនឯងពុំបាន ។ គាត់ពោលថា ទាំងទ្រព្យសម្បត្តិទាំងបុណ្យស័ក្តិ មិនមែនកើតឡើងដោយចំណេះវិជ្ជាទេ គឺកើតឡើងដោយការប្រតិបត្តិយ៉ាងពេញលេញ ។ គឺគាត់យល់ថា ទ្រព្យសម្បត្តិនិងបុណ្យស័ក្តិ កើតឡើងពីការអនុវត្តន៍ធ្វើយ៉ាងម៉ឺងម៉ាត់ ពុំមែនកើតឡើងដោយចំណេះវិជ្ជាទេ ។ ទស្សនៈរបស់គាត់នេះ មិនត្រឹមត្រូវពេញលក្ខណៈឡើយ ។ តាមព្រះពុទ្ធសាសនា ការងារដែលបានជោគជ័យល្អលុះត្រាតែមានការប្រឹងប្រែងអនុវត្តធ្វើ និងមានចំណេះដឹងជួយបំភ្លឺផ្លូវផង បើធ្វើដោយល្ងង់ខ្លៅនឹងទទួលបរាជ័យ ។ ពុទ្ធសាសនាពោលថា ធុរៈក្នុងព្រះពុទ្ធសាសនាមានពីរ គឺគន្ថធុរៈ ការសិក្សាឲ្យយល់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ និងវិបស្សនាធុរៈ ការប្រតិបត្តិតាមរហូតចាក់ធ្លុះនូវអរិយសច្ច៤ ជាធម៌រំដោះទុក្ខ ។ គាត់មានប្រសាសន៍ថា ជ័យជំនះហុចដៃឲ្យមនុស្សក្លាហាន ។ គឺជ័យជំនះគ្រប់យ៉ាង កើតមកអំពីសេចក្តីក្លាហានពុះពារឧបសគ្គគ្រប់យ៉ាង ប៉ុន្តែត្រូវក្លាហានក្នុងផ្លូវដែលត្រឹមត្រូវ ពុំមែនក្លាហានក្នុងភាពឃោរឃៅព្រៃផ្សៃឈ្លានពាន ក្នុងន័យរំលោភសិទ្ធិមនុស្សនោះឡើយ ព្រោះអំពើនោះនឹងទទួលបរាជ័យនៅពេលក្រោយ ។ គាត់មានប្រសាសន៍ថា ធម្មជាតិរបស់ទឹករមែងហូរទៅកាន់ទីទំនាប សេចក្តីអាក្រក់ក៏រមែងនាំមនុស្សទៅកាន់ទីទាប ចំណែកសេចក្តីល្អរមែងនាំមនុស្សទៅកាន់ទីខ្ពស់ ។ ការបំរើសង្គមដ៏ល្អបំផុត គឺការព្យាយាមធ្វើឲ្យសង្គមចំរើន សង្គមនឹងប្រាប់នូវសេចក្តីថោកទាប និងសេចក្តីខ្ពង់ខ្ពស់ គឺអំពើឬសកម្មភាព តែបង្ហាញនូវសេចក្តីល្អអាក្រក់របស់មនុស្ស ។ កំហុសរមែងអស់ទៅបាន ដោយការកែខៃ តែបើចេះតែក្លែងធ្វើថែមទៀត វាអាចជាខ្នុះឲ្យយើងឈឺចាប់យ៉ាងខ្លាំងមិនខាន ។ ទស្សនៈនេះរបស់គាត់ ហាក់ដូចជាស្របតាមព្រះពុទ្ធសាសនា ព្រោះប្រទេសឥណ្ឌាជាពហុវប្បធម៌ ជាវប្បធម៌ចំរុះ ដែលមានព្រះពុទ្ធសាសនានិងសាសនាហិណ្ឌូជាដើម ទោះបីគាត់មិនកាន់ព្រះពុទ្ធសាសនាក៏ដោយ ក៏គាត់អាចដកស្រង់យកពាក្យរបស់មនុស្សមកអនុវត្តក្នុងការរំដោះជាតិ ដូចលោកលើកយកធម៌អហិង្សារបស់ព្រះពុទ្ធជាមាគ៌ាអនុវត្ត ព្រោះគាត់យល់ថា រដ្ឋាភិបាលនៃប្រទេសអង់គ្លេសសុទ្ធសឹងតែជាអ្នកប្រាជ្ញចេះដឹង នឹងយកសកម្មភាពដ៏ល្អរបស់គាត់ទៅពិចារណា ។ ព្រះពុទ្ធសាសនាសំដែងថា អ្នកប្រព្រឹត្តខុសដោយមិនដឹងថាខុស មានទោសធ្ងន់ជាងអ្នកដឹងហើយធ្វើខុស ព្រោះអ្នកពុំដឹងចេះតែប្រព្រឹត្តកំហុសនោះតទៅទៀត ចំណែកអ្នកដឹងធ្វើខុសថ្ងៃណាមួយអាចលះបង់ ដូចលូកភ្លើងដឹងថាក្តៅ ថ្ងៃក្រោយមិនលូកទៀតឡើយ ។

មហាត្មគន្ធីមានប្រសាសន៍ថា មនុស្សភ្នែកខ្វាក់ មិនមែនមនុស្សភ្នែកខូចទេ មនុស្សភ្នែកខ្វាក់ គឺមនុស្សបិទបាំងទោសរបស់ខ្លួន ។ ការស្លន់ស្លោពេក ជាហេតុនាំឲ្យកើតសេចក្តីវិនាស តែភាពនៃមនុស្សមានចិត្តត្រជាក់រមែងនាំមកនូវសេចក្តីសុខយ៉ាងសុខុម ។ ចិត្តត្រជាក់គឺចិត្តស្ងប់អំពើបាប ។ ការប្រមូលបន្ថែមនូវរបស់ឲ្យមានច្រើន ដោយប្រាសចាកការចាំបាច់ ជាហេតុនាំឲ្យកើតបាប ។ ត្រង់នេះទំនងជាគាត់ចង់និយាយថា មនុស្សត្រូវមានចិត្តសន្តោសព្យាយាមរកទ្រព្យសម្បត្តិឲ្យល្មមតែរស់នៅបានសុខស្រួល កុំសន្សំវត្ថុដែលពុំមែនជាការចាំបាច់សំរាប់ជីវិត ព្រោះការលោភខ្លាំងនាំឲ្យប្រព្រឹត្តអំពើបាប ដូចជាការលួចប្លន់ជាដើម ។ គាត់មានប្រសាសន៍ថា រូបធាតុគ្រប់យ៉ាងត្រូវមានរបៀប បើប្រាសចាករបៀបសូម្បីមួយខណៈ សុរិយចក្រវាឡទាំងអស់ក៏ត្រូវដល់នៅពេលអវសានដែរ ។ ត្រង់នេះគាត់សំដៅន័យថា រូបធាតុគ្រប់យ៉ាង ធម្មជាតិបានរៀបចំយ៉ាងសម មានរបៀបរបស់វា ដូចជាផែនដី ព្រះអាទិត្យ ព្រះចន្ទជាដើម មានចលនាតាមវិថីរបស់វា ទើបកើតបានជារដូវក្តៅរដូវត្រជាក់ជាដើម ។ បើមានធម្មជាតិអ្វីមួយធ្វើឲ្យខុសដំណើរប្រក្រតីរបស់វា វានឹងបណ្តាលឲ្យកើតមានសភាពមួយផ្សេងទៀត នឹងអាចបណ្តាលឲ្យគ្រោះថ្នាក់ដល់មនុស្សលោកពុំខានឡើយ ។ ក៏ដូចជាធម្មជាតិចិត្តគំនិតរបស់មនុស្សស្រឡាញ់ខ្លួន ស្រឡាញ់សិទ្ធិសេរីភាព ស្រឡាញ់យុត្តិធម៌ ស្រឡាញ់ភាពសុខសាន្ត ស្រឡាញ់ភាពលូតលាស់ចំរើន ស្រឡាញ់ទឹកដីរបស់ខ្លួនជាដើម ។ បើមានគេធ្វើឲ្យបង្អាក់ដំណើរ ឬបំបិទសិទ្ធិ ធម្មជាតិចិត្តនេះតែងតែមានប្រតិកម្មតបវិញ ដើម្បីបានសិទ្ធិជាធម្មជាតិរបស់ខ្លួនមកវិញ ។ ឧត្តមគតិជារឿងមួយ តែការអនុវត្តន៍តាមឧត្តមគតិជារឿងមួយផ្សេងទៀត ។ ជនដែលមិនមានឧត្តមគតិ ប្រៀបដូចទូកដែលមិនមានចង្កូត ។ យើងគួរនិយាយថា យើងមានឧត្តមគតិ តែយើងក៏គួរព្យាយាមដឹកនាំខ្លួនរបស់យើង ឲ្យចូលទៅដល់ឧត្តមគតិនោះ ។ នេះជាប្រសាសន៍របស់មហាត្មគន្ធី យ៉ាងណាមិញ តាមយោបល់របស់យើង ដូចជាប្រជាជាតិមួយមានឧត្តមគតិ ឬបំណងថាត្រូវតែរំដោះជាតិ ដើម្បីសិទ្ធិរបស់ខ្លួនជាប្រជាជាតិមួយឯករាជ្យ បើខ្វះការតស៊ូដោយប្រើគ្រប់មធ្យោបាយហើយ

ក៏ពុំអាចសំរេចតាមឧត្តមគតិនោះឡើយ ។ ដូច្នេះត្រូវចាត់ឧត្តមគតិ ឬទិសដៅជាគំនិតផ្តួចផ្តើម រួមនិងមាគ៌ាត្រឹមត្រូវ ទើបសំរេចគោលដៅនេះបាន ។ មហាត្មគន្ធីមានប្រសាសន៍ថា កុំសេពគប់មិត្តណាដែលស្រឡាញ់ខ្លួនយើង តែជាសត្រូវរបស់ប្រជាជាតិយើង ។ ខ្ញុំមិនមែនជាមនុស្សបូជាវត្ថុថោកទាបទេ តែខ្ញុំជាមនុស្សគោរពទំនៀមប្រពៃណី ដែលខ្ញុំយល់ឃើញថាល្អ ដែលខ្ញុំធ្វើយ៉ាងនេះ ក៏ដើម្បីទាញអារម្មណ៍របស់មនុស្សសម័យថ្មី ឲ្យមានសេចក្តីស្នេហាចំពោះវត្ថុបូរាណរបស់ជាតិ ។ ខ្ញុំសូមសារភាពថា ខ្ញុំជាមនុស្សបូជាប្រពៃណីបូរាណ ខ្ញុំមិនសូវចូលចិត្តមនុស្សនិយមសម័យថ្មីហួសពេក រហូតដល់ប្រមាថមើលងាយប្រពៃណីបូរាណឡើយ ។

ប្រសាសន៍របស់មហាត្មគន្ធី ទោះបីពាក្យខ្លះមិនស្របតាមព្រះពុទ្ធសាសនាក៏ដោយ តែបានជាអនុសាសន៍មួយសំរាប់អ្នកដឹកនាំរដ្ឋសម័យបច្ចុប្បន្នយកមកពិចារណា ដើម្បីរៀបចំប្រទេសរបស់ខ្លួនឲ្យបានសុខសន្តិភាព និងចំរើនលូតលាស់ ។៚

*   *

*